**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខ:..១៦៦..សសរ**

# សេចក្តីសម្រេច

## ស្តីពី

## ការបង្កើតគណៈកម្មាធិការត្រួតពិនិត្យគ្រឿងញៀនរាជធានី ខេត្ត

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២១៣/១៣៩៣ ចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១៣ ស្តីពីការកែសម្រួលនិងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៣០១/០៥ ចុះថ្ងៃទី១៩ ខែមីនា ឆ្នាំ២០០១ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៧ ចុះថ្ងៃទី២២ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១១២/០០១ ចុះថ្ងៃទី០២ ខែមករា ឆ្នាំ២០១២ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៥០៩/៦០៨ ចុះថ្ងៃទី៣០ ខែឧសភា ឆ្នាំ២០០៩ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន
- យោងតាមសំណើរបស់ប្រធានអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន/.



www.pheakdeylaw.com

## សម្រេច

**ប្រការ១ .-**

ត្រូវបានបង្កើតគណៈកម្មាធិការត្រួតពិនិត្យគ្រឿងញៀនរាជធានី ខេត្តនៅតាមរាជធានី ខេត្ត ដូចខាងក្រោម៖

១- រាជធានីភ្នំពេញ
២- ខេត្តកណ្តាល
៣- ខេត្តកំពង់ចាម
៤- ខេត្តបាត់ដំបង
៥- ខេត្តព្រៃវែង
៦- ខេត្តសៀមរាប
៧- ខេត្តតាកែវ
៨- ខេត្តត្បូងឃ្មុំ
៩- ខេត្តបន្ទាយមានជ័យ
១០- ខេត្តកំពង់ស្ពឺ
១១- ខេត្តកំពង់ធំ
១២- ខេត្តកំពត
១៣- ខេត្តកំពង់ឆ្នាំង
១៤- ខេត្តស្វាយរៀង
១៥- ខេត្តពោធិ៍សាត់
១៦- ខេត្តក្រចេះ
១៧- ខេត្តព្រះសីហនុ
១៨- ខេត្តកោះកុង
១៩- ខេត្តព្រះវិហារ
២០- ខេត្តរតនគិរី
២១- ខេត្តស្ទឹងត្រែង
២២- ខេត្តឧត្តរមានជ័យ
២៣- ខេត្តមណ្ឌលគិរី
២៤- ខេត្តប៉ៃលិន
២៥- ខេត្តកែប

**ប្រការ២ .-**

គណៈកម្មាធិការត្រួតពិនិត្យគ្រឿងញៀននៅតាមរាជធានី ខេត្ត នីមួយៗមានសមាសភាពដូចខាងក្រោម៖

| | |
|---|---|
| - អភិបាលនៃគណៈអភិបាលរាជធានី ខេត្ត | ប្រធាន |
| - អភិបាលរងរាជធានី ខេត្ត១រូប | អនុប្រធាន |
| - ស្នងការនគរបាលរាជធានី ខេត្ត | សមាជិក |
| - មេបញ្ជាការកងរាជអាវុធហត្ថរាជធានី ខេត្ត | សមាជិក |
| - មេបញ្ជាការឬតំណាងយោធភូមិភាគ(ចំពោះខេត្តដែលមានយោធភូមិភាគឈរជើង) | សមាជិក |
| - មេបញ្ជាការឬតំណាងកងនាវាចរខេមរភូមិន្ទមូលដ្ឋានដែនសមុទ្រ(ចំពោះខេត្តដែលមានកងនាវាចរខេមរភូមិន្ទឈរជើង) | សមាជិក |
| - មេបញ្ជាការតំបន់ប្រតិបត្តិការសឹករងខេត្ត | សមាជិក |
| - មេបញ្ជាការកងពលតូច ៧០(ចំពោះរាជធានីភ្នំពេញ) | សមាជិក |
| - ប្រធានមន្ទីរអប់រំ យុវជន និងកីឡារាជធានី ខេត្ត | សមាជិក |
| - ប្រធានមន្ទីរសុខាភិបាលរាជធានី ខេត្ត | សមាជិក |
| - ប្រធានមន្ទីរសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទារាជធានី ខេត្ត | សមាជិក |
| - ប្រធានមន្ទីរការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈរាជធានី ខេត្ត | សមាជិក/ |



www.pheakdeylaw.com

- ប្រធានមន្ទីរប្រៃសណីយ៍និងទូរគមនាគមន៍រាជធានី ខេត្ត សមាជិក
- ប្រធានមន្ទីរកិច្ចការនារីរាជធានី ខេត្ត សមាជិក
- ប្រធានមន្ទីរវប្បធម៌និងវិចិត្រសិល្បៈរាជធានី ខេត្ត សមាជិក
- ប្រធានមន្ទីរកសិកម្មរាជធានី ខេត្ត សមាជិក
- ប្រធានមន្ទីរធម្មការនិងសាសនារាជធានី ខេត្ត សមាជិក
- ប្រធានមន្ទីរឧស្សាហកម្មនិងសិប្បកម្មរាជធានី ខេត្ត សមាជិក
- ប្រធានមន្ទីរព័ត៌មានរាជធានី ខេត្ត សមាជិក
- ប្រធានមន្ទីរសេដ្ឋកិច្ចនិងហិរញ្ញវត្ថុរាជធានី ខេត្ត សមាជិក
- ប្រធានមន្ទីរទេសចរណ៍រាជធានី ខេត្ត សមាជិក
- ប្រធានសាខាគយនិងរដ្ឋាកររាជធានី ខេត្ត សមាជិក
- ប្រធានសាខាកាំកុងត្រូលរាជធានី ខេត្ត សមាជិក

សមាសភាពជាក់ស្តែងនៃគណៈកម្មាធិការត្រួតពិនិត្យគ្រឿងញៀននៅតាមរាជធានី ខេត្ត នីមួយៗ ត្រូវតែងតាំងដោយសេចក្តីសម្រេចរបស់ប្រធានអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន។

**ប្រការ៣ .-**

គណៈកម្មាធិការត្រួតពិនិត្យគ្រឿងញៀនរាជធានី ខេត្ត មានភារកិច្ចដូចតទៅ៖

**ក- ចំពោះខេត្ត ដែលមានព្រំប្រទល់ជាប់ប្រទេសថៃ ឡាវ វៀតណាម៖**

- សហប្រតិបត្តិការនិងសម្របសម្រួលផែនការប្រយុទ្ធប្រឆាំងគ្រឿងញៀនរវាងខេត្ត នៃប្រទេសជិតខាងដែលមានព្រំប្រទល់ជាប់គ្នា
- ធ្វើឱ្យកាន់តែប្រសើរឡើងនូវការផ្លាស់ប្តូរព័ត៌មានតាមព្រំដែន រាល់បញ្ហាដែលពាក់ព័ន្ធនឹងការដាំដុះ ការផលិត ការចរាចរ ការជួញដូរ ការប្រើបំពានគ្រឿងញៀន និងការចរាចរសារធាតុគីមីផ្សំ
- បង្កើតនីតិវិធីរួមមួយ សម្រាប់ទំនាក់ទំនងខាងបណ្តាញផ្លាស់ប្តូរប្រមូលព័ត៌មានពីគ្នាទៅវិញទៅមករវាងខេត្តនៃប្រទេសជិតខាងដែលមានព្រំប្រទល់ជាប់គ្នាដូចមានចែងក្នុងអនុស្សរណៈនៃការយោគយល់គ្នា
- បង្កើតឱ្យមានទំនាក់ទំនងជិតស្និទ្ធជាមួយមន្ត្រីក្នុងវិស័យផ្សេងៗ សម្រាប់ការងារត្រួតពិនិត្យគ្រឿងញៀនដោយឈរលើស្មារតីគិតគូរដល់ផលប្រយោជន៍រួម
- រៀបចំឱ្យមានកម្មវិធីជួបប្រជុំជាប្រចាំជាមួយភាគីនៃខេត្តជាប់ព្រំដែននៃប្រទេសជិតខាងឱ្យបានទៀងទាត់ដើម្បីពិភាក្សានិងកសាងផែនការសកម្មភាពរួមគ្នា និងពង្រីកកិច្ចសហប្រតិបត្តិការនេះ
- គ្រប់គ្រងនិងដឹកនាំការិយាល័យទំនាក់ទំនងព្រំដែនលើបញ្ហាគ្រឿងញៀន(BLO)។

ក្រៅពីភារកិច្ចខាងលើ ខេត្តដែលជាប់ព្រំដែនក៏ត្រូវបំពេញភារកិច្ចដូចរាជធានី ខេត្ត នៅក្នុងផ្ទៃប្រទេសដែលមានចែងអំពីភារកិច្ច ក្នុងចំណុច"ខ"ខាងក្រោមនេះដែរ។

**ខ- ចំពោះរាជធានី ខេត្ត នៅក្នុងផ្ទៃប្រទេស៖**

- កសាងផែនការសកម្មភាពប្រយុទ្ធប្រឆាំងគ្រឿងញៀនថ្នាក់រាជធានី ខេត្តរបស់ខ្លួន ដោយយកចិត្តទុកដាក់ សំខាន់៖



www.pheakdeylaw.com

• ការងារពង្រឹងសមត្ថភាពមន្ត្រីអនុវត្តច្បាប់អំពីច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន វិធានការស៊ើបអង្កេត ស្រាវជ្រាវ ទប់ស្កាត់ និងបង្ក្រាបបទល្មើសពាក់ព័ន្ធនឹងការផលិត ការដាំដុះ ការចរាចរ ការជួញដូរ ការប្រើបំពានគ្រឿងញៀន សារធាតុគីមីផ្សំ និងនីតិវិធីកសាងសំណុំរឿងបញ្ជូនទៅតុលាការ
• ការងារអប់រំបង្ការ ការពារការប្រើបំពានគ្រឿងញៀន តាមរយៈយុទ្ធនាការឃោសនា ផ្សព្វផ្សាយ ធ្វើឱ្យមានការយល់ដឹងជាទូទៅអំពីគ្រោះថ្នាក់ ដែលបណ្តាលមកពីការប្រើបំពានគ្រឿងញៀន
• រៀបចំឱ្យមានកម្មវិធីនិងកន្លែងសម្រាប់ព្យាបាលអ្នកញៀនគ្រឿងញៀន នៅក្នុងរាជធានី ខេត្ត របស់ខ្លួន

- រៀបចំឱ្យមានប្រព័ន្ធផ្លាស់ប្តូរព័ត៌មានពីរាជធានី ខេត្តមួយទៅខេត្តមួយ រាល់បញ្ហាដែលពាក់ព័ន្ធនឹងការផលិត ការដាំដុះ ការចរាចរ ការជួញដូរ និងការប្រើបំពានគ្រឿងញៀននិងសារធាតុគីមីផ្សំ
- ប្រមូលផ្តុំការដឹកនាំដល់មន្ត្រីដែលស្ថិតក្នុងវិស័យផ្សេងៗដែលពាក់ព័ន្ធដល់ការត្រួតពិនិត្យគ្រឿងញៀន សំដៅធ្វើឱ្យមានប្រសិទ្ធភាពខ្ពស់
- ចូលរួមប្រជុំតាមការអញ្ជើញរបស់អគ្គលេខាធិការនៃអគ្គលេខាធិការដ្ឋានអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន
- ធ្វើរបាយការណ៍ប្រចាំខែ ត្រីមាស ឆមាស នព្វមាសនិងប្រចាំឆ្នាំ និងរាយការណ៍ភ្លាមៗជាបន្ទាន់ក្នុងករណីពិសេស មកអគ្គលេខាធិការដ្ឋាននៃអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន
- អនុវត្តភារកិច្ចផ្សេងៗទៀតដែលប្រធានអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀនប្រគល់ជូន។

**ប្រការ៤ ._**

ទីតាំងរបស់គណៈកម្មាធិការត្រួតពិនិត្យគ្រឿងញៀនរាជធានី ខេត្ត អាស្រ័យដោយប្រធានគណៈកម្មាធិការជាអ្នកសម្រេច។ គណៈកម្មាធិការត្រួតពិនិត្យគ្រឿងញៀនរាជធានី ខេត្តមានសិទ្ធិប្រើត្រារបស់រាជធានី ខេត្ត ដើម្បីដំណើរការការងាររបស់ខ្លួន។

**ប្រការ៥ ._**

គណៈកម្មាធិការនេះ មានលេខាធិការដ្ឋានមួយជាសេនាធិការ ក្នុងការដឹកនាំ គ្រប់គ្រង លើកផែនការ តាមដាន វាយតម្លៃ ការអនុវត្តការងារប្រយុទ្ធប្រឆាំងគ្រឿងញៀន។

អនុប្រធានគណៈកម្មាធិការត្រួតពិនិត្យគ្រឿងញៀនរាជធានី ខេត្ត គឺជាប្រធានលេខាធិការដ្ឋាននេះ។

**ប្រការ៦ ._**

ប្រធានគណៈកម្មាធិការត្រួតពិនិត្យគ្រឿងញៀនរាជធានី ខេត្ត ត្រូវរៀបចំបង្កើតឱ្យមានគណៈកម្មាធិការត្រួតពិនិត្យគ្រឿងញៀន នៅថ្នាក់ខណ្ឌ ក្រុង ស្រុក និងឃុំ សង្កាត់ ដើម្បីបំពេញភារកិច្ចប្រយុទ្ធប្រឆាំងគ្រឿងញៀននៅថ្នាក់មូលដ្ឋាន។

អភិបាលនៃគណៈអភិបាលរាជធានី ខេត្ត ដែលជាអាណាប័កផ្ទេរសិទ្ធិ ត្រូវម្ចាស់ការក្នុងការរៀបចំបង្កើតឱ្យមានកញ្ចប់ថវិកាដោយឡែក សម្រាប់ការងារប្រយុទ្ធប្រឆាំងគ្រឿងញៀនប្រចាំឆ្នាំនៅក្នុងរាជធានី ខេត្តរបស់ខ្លួន។

**ប្រការ៧ ._**

សេចក្តីសម្រេចលេខ០៩ សសរ ចុះថ្ងៃទី២៥ ខែកុម្ភៈ ឆ្នាំ២០០៤ ស្តីពីគណៈកម្មាធិការត្រួតពិនិត្យគ្រឿងញៀនខេត្ត ក្រុង និងបទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងសេចក្តីសម្រេចនេះ ត្រូវទុកជានិរាករណ៍។/.



www.pheakdeylaw.com

**ប្រការ៨ .-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ប្រធានអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងការពារជាតិ រដ្ឋមន្ត្រីគ្រប់ក្រសួង ប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ និងអភិបាលនៃគណៈអភិបាលរាជធានី ខេត្ត ត្រូវទទួលបន្ទុកអនុវត្តសេចក្តីសម្រេចនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ១៧ ខែ ធ្នូ ឆ្នាំ២០១៤

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល :**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្តម លោកជំទាវឧបនាយករដ្ឋមន្ត្រី
- ដូចប្រការ៨
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ



www.pheakdeylaw.com